ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥១៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០១២

អនុលោមតាមមាត្រា ៥ និងមាត្រា ២៩ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ សូមជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ២០១២ ដូចខាងក្រោម :

១. សហគ្រាសដែលប្រើប្រាស់ឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន (០១ ខែមករា ដល់ ៣១ ខែធ្នូ) ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១២ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែ មីនា ឆ្នាំ២០១៣ នៅរដ្ឋបាលសារពើពន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងប្រមូលពន្ធលើសហគ្រាស ។

២. សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ ។

៣. សហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើមនិងគ្រប់សាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លទ្ធផលចំណេញ-ខាតរបស់សាខានីមួយៗ ។ គ្រឹះស្ថានដែលជាសាខានីមួយៗ ត្រូវប្រកាសលទ្ធផលចំណេញ-ខាតសាខារបស់ខ្លួនតាមគំរូលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងដាក់ជូនរដ្ឋបាលសារពើពន្ធ នៅទីកន្លែងដែលសាខាជាប់ទាក់ទិននីមួយៗតាំងនៅ ។

៤. សហគ្រាសដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលគ) ច្រើន ឬអនុវត្តគម្រោងដទៃទៀតច្រើនដែលជាគម្រោង គលគ ផង និងមិនមែនជា គលគ ផង ហើយដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញខុសគ្នា ឬត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដូចមានចែងក្នុងចំណុច ១ ដល់ ៣ ខាងលើ និងត្រូវអនុវត្តតាមការណែនាំបន្ថែមដោយឡែករបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៥. ចំពោះតំណាងអ្នកជាប់ពន្ធដែលទទួលបន្ទុក ធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ ដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឱ្យអ្នកជាប់ពន្ធ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធដូចមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ស្តីពីសារពើពន្ធ ។

អគ្គនាយកដ្ឋានពន្ធដារ សូមថ្លែងអំណរគុណចំពោះសហគ្រាសមួយចំនួន ដែលកន្លងមកបំពេញលិខិតប្រកាសពន្ធបានត្រឹមត្រូវ ដាក់ជូនរដ្ឋបាលសារពើពន្ធ និងបានប្រកាសបង់ពន្ធលើប្រាក់ចំណេញត្រឹមត្រូវទាន់ពេលវេលា ។

ក្នុងករណី លោក-លោកស្រី មានចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយ ការិយាល័យចុះបញ្ជីនិងសេវាអ្នកជាប់ពន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្ត ដែលទាក់ទិន ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាស ពិតជាយកចិត្តទុកដាក់ អញ្ជើញមកដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញ តាមច្បាប់កំណត់ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

គង់ វិបុល